ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខៈ ៤៧
ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩
សាលដីកា
លេខៈ ៨០ "V"
ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ប្រធាន
២.លោក [redacted] ចៅក្រម
៣.លោក [redacted] ចៅក្រម
៤.លោក [redacted] ចៅក្រម
៥.លោក [redacted] ចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២១៥ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ច័ន្ទមុនី ជាដើមបណ្តឹងរដ្ឋប្បវេណីចំពោះសាលដីកាព្រហ្មទណ្ឌលេខ ២៩ សស.ក្រ.VII "ធ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ដែលមាន ៖

-ជនត្រូវចោទ៖

១-ឈ្មោះ [redacted] យ៉ន ភេទស្រី អាយុ៦៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted] មានកូន០៥ នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ចុងបណ្តឹងសាទុក្ខ) (ក្រៅឃុំ)

Scanned with CamScanner

ខ-ឈ្មោះ [redacted] ចំរើន ភេទស្រី អាយុ៦០ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅសព្វថ្ងៃនៅភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ម៉េម៉ាយ ជានីតិជន ទោសពីមុនគ្មាន ។ (ចុងបណ្ដឹងសាទុក្ខ) (ក្រៅឃុំ)

<u>ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ:</u> **អំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងលួចលក់អចលនវត្ថុមិនមែនជារបស់ខ្លួន** ប្រព្រឹត្តនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២៥៣ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល ។

-មានលោក [redacted] សុជាតិ ជាមេធាវីការពារ

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទមុនី ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល។ (អ្នកប្ដឹងសាទុក្ខ)

**អំពីអង្គហេតុ**

តាមពាក្យបណ្ដឹងចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ បានរៀបរាប់ថា៖ ខ្លួនបានកាន់កាប់ដីដែលមានទំហំ១៨ម គុណនឹង ២០០ម ដែលមានទីតាំងស្ថិតនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ក្រោយមកខ្លួនបានលក់កន្ទុយដី ហើយដីនៅសល់ ទទឹងទំហំ ២៩,៣ ម៉ែត្រ បណ្ដោយទំហំប្រវែង ១៧,៦ ម៉ែត្រ បានកាន់កាប់ និងធ្វើរបង និងដាំដំណាំលើដីនោះរហូតមក ស្រាប់តែនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៧ ឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted] ចំរើន បានដកបង្គោលព្រំដី និងកាប់បង្គោលព្រំដីរបស់ខ្លួនដែលបានដាំនៅលើដីរបស់ខ្លួន ។ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ ឈ្មោះ [redacted] យ៉ន និង ឈ្មោះ [redacted] ចំរើន បានទៅដកបង្គោលព្រំដីម្ដងទៀត និងយកដីរបស់ខ្លួនយកទៅលក់ឱ្យគេ ។

បានឃើញ ដីកាដំណោះស្រាយលេខ ៥០៣ "ដកដស" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

លើកលែងការចោទប្រកាន់លើជនត្រូវចោទ៖ឈ្មោះ [redacted] យ៉ន ភេទស្រី អាយុ៦៥ឆ្នាំ និងឈ្មោះ [redacted] ចំរើន ភេទស្រី អាយុ៦០ឆ្នាំ ពីបទ៖ អំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងលួចលក់អចលនវត្ថុមិនមែនជារបស់ខ្លួន ប្រព្រឹត្តនៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២៥៣ និងមាត្រា២៥៥ នៃច្បាប់ភូមិបាល។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ០០៧ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ច័ន្ទមុនី ដែលប្ដឹងមិនសុខចិត្តនឹងដីកាដំណោះស្រាយលេខ ៥០៣ "ដកដស" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ ២៩ "សស.ក្រVII.ធ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖



Scanned with CamScanner

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ច័ន្ទមុនី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់ដីកាដំណោះស្រាយលេខ ៤០៣ "ដកដស" ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល ទុកជាបានការដដែល ។

៣-សាលដីកានេះប្រកាសជាអសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ។

បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២១៥ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទមុនី ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ២៩ "សស.ក្រVII.ធ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

## នាពេលសវនាការ

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានសុំថា៖ សភាស៊ើបសួរសាលាឧទ្ធរណ៍ដែលបានសម្រេចមកនេះឃើញថា មានលក្ខណៈត្រឹមត្រូវហើយ ព្រោះថាការលើកឡើងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងជនជាប់ចោទសុទ្ធតែអះអាងថាដីដែលបានលក់អោយអ្នកដទៃជាដីរបស់ខ្លួន ហើយសាលាឧទ្ធរណ៍ក៏បានលើកមកបញ្ជាក់ក្នុងសំអាងហេតុរួចហើយ និងមានលក្ខណៈត្រឹមត្រូវ ។

**តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច៖**

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៩ "សស.ក្រVII ធ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ច័ន្ទមុនី បានឆ្លើយថា៖ ខ្ញុំប្ដឹងសាទុក្ខមកនេះ ព្រោះខ្ញុំចង់បានដីមកវិញ ព្រោះគេបានលួចដីខ្ញុំលក់ យកលុយមកចាយ ការលក់នេះមានគ្នា០៣នាក់ ឱ្យលុយគាត់តែម្នាក់ ០២ នាក់ទៀតមិនឱ្យលុយទេ ដីនេះមានប្លង់ជារបស់ខ្ញុំ ។

សំណូមពរ ខ្ញុំសូមឱ្យតុលាការសម្រេច ឱ្យដីមកខ្ញុំវិញ។

-លោក [redacted] សុជាតិ ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទទាំងពីរ បានធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្នុងរឿងនេះ អង្គហេតុគឺដូចតុលាការថ្នាក់ក្រោមបានសម្រេច ទាក់ទងនិងដីនេះ គឺអ្នកស្រី [redacted] ច័ន្ទមុនី គាត់បានលក់ដីនេះតាំងពីឆ្នាំ២០១៧ ហើយកូនក្ដីខ្ញុំបានលក់នៅឆ្នាំ២០១៨ នៅពេលដែលកូនក្ដីខ្ញុំលក់ លោកស្រី [redacted] ច័ន្ទមុនី និយាយថា ដីគាត់នៅសល់ ប៉ុន្តែកាលពីពេលដែលលោកស្រីលក់ គឺមានឯកសារព្រំប្រទល់ច្បាស់លាស់តាំងពីឆ្នាំ២០១៧ថា ដីទល់និងឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] យ៉ន ដូច្នេះហើយលោកស្រីគ្មាននៅសល់ដីទៀតទេ។

Scanned with CamScanner

សំណូមពរ សូមក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ២៩ ស.ស ក្រ.VIIធ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល ។

-ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីសន្និដ្ឋានការពារក្ដី

របស់មេធាវីជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ២១៥ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ច័ន្ទមុនី ជាដើមបណ្ដឹង ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន។

២-យល់ឃើញថា តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាម្ចាស់បណ្ដឹងសាទុក្ខ បានឆ្លើយចំពោះមុខសវនាការតុលាការកំពូលថា បណ្ដឹងសាទុក្ខមកតុលាការកំពូលនេះ គឺក្នុងគោលបំណងទាមទារដីរបស់ខ្លួន ដែលជនជាប់ចោទឈ្មោះ [redacted] យ៉ន និងឈ្មោះ [redacted] ចំរើន លក់ឱ្យទៅតតិយជន។ ការលើកឡើងនេះត្រូវបានមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទលើកឡើង នៅចំពោះមុខតុលាការកំពូលថា ដីរបស់ដើមបណ្ដឹងបានលក់ឱ្យក្រុមហ៊ុនមុន ចំណែកកូនក្ដីខ្លួនលក់ក្រោយ ហើយបើពិនិត្យទៅលើលិខិតលក់ទិញរបស់ដើមបណ្ដឹង ព្រំខាងកើតទល់នឹងឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] យ៉ន បើគាត់មានដីនៅសល់ ប្រាកដជាមានដាក់ព្រំប្រទល់ទល់នឹងដីរបស់ដើមបណ្ដឹងជាក់ជាមិនខាន។ តុលាការកំពូលពិចារណា លើសំអាងហេតុរបស់គូភាគី ដើមបណ្ដឹងរដ្ឋប្បវេណី មានគោលបំណងទាមទារដីដែលជាសមត្ថកិច្ចតុលាការរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ដូច្នេះ ឃើញថាពុំឃើញមានធាតុផ្សំនៃបទហិង្សា ដោយចេតនាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត និងបទលួចលក់អចលនវត្ថុអ្នកដទៃ តាមមាត្រា២៥៣ និង២៥៥ នៃច្បាប់ភូមិបាល ប្រព្រឹត្តកាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ នៅភូមិកណ្ដាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្ដាល ទេ ។

៣-យល់ឃើញថា បណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានមូលហេតុតាមមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលគប្បីតុលាការកំពូលបដិសេធបណ្ដឹងសាទុក្ខនេះចោល ។

៤-យល់ឃើញថា សាលដីកាសភាស៊ើបសួរលេខ ២៩ “សស.ក្រVII.ធ” ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះត្រឹមត្រូវតាមគតិច្បាប់ហើយ។



Scanned with CamScanner

## ហេតុដូច្នេះ

## សម្រេច

១-បដិសេធបណ្តឹងសាទុក្ខលេខ២១៥ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ច័ន្ទមុនី ជាដើមបណ្តឹងរដ្ឋប្បវេណី។

២-តម្កល់សាលដីកាសភាស៊ើបសួរលេខ ២៩ “សស.ក្រVII.ធ” ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការ ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner